# របាយការណ៍ប្រចាំខែ មិថុនា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ

## ១. សេចក្តីផ្តើម

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណ ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹង ខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

## ២. ស្ថានភាពរបស់មន្ទីរ

### ២.១ ការងាររដ្ឋបាល និងបុគ្គលិក

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប និងរួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

### ២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ថ្ងៃទី២៦ ខែឧសភា លោកប្រធានមន្ទីរ និងប្រធានការិយាល័យផ្លូវជនបទ ចូលរួមប្រជុំរៀបចំផែនការថែទាំផ្លូវខួប និងប្រចាំ ឆ្នាំ ២០១៦ របស់នាយកដ្ឋានផ្លូវជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ រាជធានីភ្នំពេញ
- ថ្ងៃទី០២ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីបិទផ្សាយតំបន់វិនិច្ឆ័យ និងប្រកាសបើកការវាស់វែងដីធ្លីជាប្រព័ន្ធនៅក្រុងសំរោងក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលាក្រុងសំរោង
- ថ្ងៃទី០៤ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំផ្សព្វផ្សាយសេចក្តីណែនាំ និងគំរូរបាយកាណ៍ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តឧត្តរមានជ័យ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្ត
- ថ្ងៃទី០៤ ខែមិថុនា មន្ត្រីការិយាល័យរដ្ឋបាល ចូលរួមប្រជុំសាមញ្ញលើកទី ១៣ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី ២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្តឧត្តរមានជ័យ នៅសាលប្រជុំសាលាខេត្ត
- ថ្ងៃទី០៤ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យរដ្ឋបាល ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តស្តីពីការរៀបចំផែនការសកម្មភាពកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយក្នុងវិស័យកសិកម្មនៅសាលប្រជុំមន្ទីរកសិកម្មខេត្ត

- ថ្ងៃទី០៦ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមពិធីផ្សព្វផ្សាយអនុសិរវច្ចៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងខេត្តលើកទី ២៣ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំមន្ទីរទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- ថ្ងៃទី០៨ ខែមិថុនា មន្ត្រីការិយាល័យរដ្ឋបាល ចូលរួមប្រជុំទទួលផែនការណែនាំធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ តាមគម្រូថ្មី នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី០៨ ខែមិថុនា មន្ត្រីការិយាល័យរដ្ឋបាល ចូលរួមប្រជុំបណ្តាញការងារយេនឌ័រថ្នាក់ខេត្តប្រចាំឆមាសទីមួយ ឆ្នាំ២០១៥ នៅសាលប្រជុំមន្ទីរកិច្ចការនារី ខេត្តឧត្តរមានជ័យ
- ថ្ងៃទី១២ ខែមិថុនា លោកប្រធានមន្ទីរ ចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី ៨ ថ្ងៃបង្កើតសមាគមអតីយុទ្ធជនកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **ស ថាវី** អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ នៅសាលប្រជុំមន្ទីរទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ច
- ថ្ងៃទី១៧ ខែមិថុនា លោកប្រធានមន្ទីរ ចូលរួមចរចាថ្លៃលើការងារថែទាំផ្លូវជាលក្ខណៈខួបចំនួន ០៨ គម្រោង ស្ថិតនៅខេត្តកំពង់ឆ្នាំង ខេត្តឧត្តរមានជ័យ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តប៉ៃលិន និងខេត្តត្បូងឃ្មុំ អនុវត្តដោយ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងនាយកដ្ឋានផ្លូវជនបទ ប្រើប្រាស់ថវិកាជំពូក ៦១ ក្រោមអធិបតីភាព ឯកឧត្តម **ហួត សារឹម** សមាជិកគណៈកម្មាធិការលទ្ធកម្ម និងជាអនុរដ្ឋលេខាធិការ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី១៩ ខែមិថុនា មន្ត្រីការិយាល័យគណនេយ្យចំនួន ០២ រូប ចូលរួមផ្សព្វផ្សាយសារាចរណែនាំលេខ ០០៥ ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងឆ្នាំ ២០១៦ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- ថ្ងៃទី២២ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរចូលរួមវេទិការសហគមន៍ ស្តីពីការលើកកម្ពស់សីលធម៌ តម្លៃស្រ្តី និងគ្រួសារខ្មែរ ក្រោមប្រធានបទ (រំលឹកគុណមាតា បិតា សីលធម៌សង្គម) នៅមន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ និង
- ថ្ងៃទី២៤ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំបូកសរុបលទ្ធផលប្រចាំខែមិថុនា របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ នៅសាលប្រជុំសាលាខេត្តឧត្តរមានជ័យ។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះត្រួតពិនិត្យការដ្ឋានផ្លូវថែទាំខួបឆ្នាំ ២០១៥ រួមមាន កំពុងសាងសង់លូប្រអប់ ០៣ ប្រឡោះ ០១ កន្លែង និងលូភ្លោះ ០១ កន្លែង រួចរាល់បាន ៧០% ចាក់ដីបំពេញត្នួផ្លូវប្រវែង ៩ ២០០ ម៉ែត្រ ចាប់ពីភូមិគោកមន ឃុំគោកមន ដល់ភូមិតាម៉ា ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ
- ចុះប្រមូលទិន្នន័យខ្សែផ្លូវក្នុងស្រុកបន្ទាយអំពិល បានប្រវែងចំនួន ១៥ គីឡូម៉ែត្រ និងក្រុងសំរោង

បានប្រវែងចំនួន ១០ គីឡូម៉ែត្រ និង

- ចុះត្រួតពិនិត្យការងារក្រាលគ្រួសក្រហម ក្នុងស្រុក/ក្រុងចំនួន ៤ គឺក្នុងក្រុងសំរោង ស្រុកបន្ទាយអំពិល ស្រុកអន្លង់វែង និងស្រុកចុងកាល់ សរុបទាំងអស់បានប្រវែង ៩ ៣៩៧ ម៉ែត្រ គាំទ្រដោយគម្រោងឧបត្ថម្ភស្បៀងបន្ទាន់។

## ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ០១ អណ្តូង មានទីតាំងនៅក្នុងកងពលតូចអន្តរាគមន៍លេខ ៤ ភូមិក្រឡូសែនជ័យ ឃុំបេង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ អនុវត្តដោយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ និង
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ ០៧ អណ្តូង មានទីតាំងនៅកងពលតូចអន្តរាគមន៍លេខ ៥ ភូមិសែនជ័យ ១ សែនជ័យ ២ និងភូមិសែនជ័យ ៥ ឃុំបេង ស្រុកបន្ទាយអំពិល ខួងមានទឹកចំនួន ០៤ កន្លែង អនុវត្តដោយនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ។

## ៣.៣ ការិយាល័យស្រុក/ក្រុង

- ប្រធានការិយាល័យស្រុកចុងកាល់ ចូលរួមវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាស្រុកចុងកាល់ អាណត្តិទី ២ នៅឃុំចុងកាល់ ឃុំក្រសាំង និងឃុំពង្រ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និង
- ប្រធានការិយាល័យស្រុកបន្ទាយអំពិល ចូលរួមវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាស្រុកបន្ទាយអំពិល អាណត្តិទី ២ នៅវត្តគោកមន និងវត្តគោកខ្ពស់ ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

## ៣.៤ ការងារភូមិអភិវឌ្ឍន៍គំរូ

### ៣.៤.១ ការងារសាងសង់ផ្លូវ

- ភូមិតាមាន់សែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហម០១ ខ្សែ មាន ០៥ កំណាត់ ប្រវែង ៨ ៤០០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ សំណង់សិល្បការគ្រប់ប្រភេទ ២៧ កន្លែង សម្រេចបានលទ្ធផល ៥០ ភាគរយ
- ភូមិប្រាសាទក្រហមសែនជ័យ÷ ផ្លូវក្រាលគ្រួសក្រហមមាន ០៧ កំណាត់ ប្រវែងសរុប ១២ ០០០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ (ផ្លូវមេប្រវែង ៤ ៥០០ ម៉ែត្រ ) និងលូមូលចំនួន ២០ កន្លែង សម្រេចបានលទ្ធផល ៣០ ភាគរយ និង
- ភូមិពពេលសែនជ័យ÷ មិនទាន់អនុវត្ត ដោយសារភ្លៀងធ្លាក់ ។

### ៣.៤.២ ការងារសាងសង់អណ្តូង

- កងពលតូចអន្តរាគមន៍លេខ ៤ (ភូមិក្រឡូសែនជ័យ)÷ ខួងបាន ០១ កន្លែង មានទឹកមិនទាន់តម្លើងក្បាលស្នប់
- កងពលតូចអន្តរាគមន៍លេខ ៥ (ភូមិសែនជ័យ ១,សែនជ័យ ២,សែនជ័យ ៥)÷ ខួងបាន ០៧

កន្លែង មានទឹក ០៤ កន្លែង មិនទាន់តម្លើងក្បាលស្នប់ និង

- សរុបអណ្តូងខូងបាន ០៨ កន្លែង មានទឹក ចំនួន ០៥ កន្លែង។

**៤. ទិសដៅការងារបន្ត**

- ចុះតាមដានត្រួតពិនិត្យការងារកំពុងអនុវត្ត ថៃទាំខូបឆ្នាំ ២០១៥
- ចុះប្រមូលទិន្នន័យខ្សែផ្លូវបន្តទៀតតាមតារាងផែនការឆ្នាំ ២០១៥
- សាងសង់អណ្តូងស្នប់ចំនួន ១៩ អណ្តូង រួមមាន នៅស្រុកបន្ទាយអំពិល ០៨ អណ្តូង ស្រុកត្រពាំងប្រាសាទ ០៨ អណ្តូង ក្រុងសំរោង ០២ អណ្តូង និងស្រុកចុងកាល់ ០១ អណ្តូង និង
- រៀបចំប្រមូលទិន្នន័យអនាម័យភូមិ ចំនួន ៤៣ ភូមិ របស់កម្មវិធីអង្គការ Unicef ។